**BMI0088**

# សម្ភាសន៍ជាមួយឈ្មោះ យាយ អ៊ូម ភេទស្រី អាយុ៦៤ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ក្រងស្បូវ

## សព្វថ្ងៃរស់នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ស៊ិន សុធីតា

០០:៥៩:៣១

២១ទំព័រ

ធីតាៈ អ៊ំឈ្មោះអីដែរ?

អ៊ូមៈ ឈ្មោះយាយ អ៊ូម!

ធីតាៈ អាយុប៉ុន្មានអ៊ំ?

អ៊ូមៈ អាយុ៦៤!

ធីតាៈ មានស្រុកកំណើតនៅណាដែរ?

អ៊ូមៈ ស្រុកកំណើតនៅភូមិផ្គាំ ឃុំផ្គាំ!

ធីតាៈ ស្រុក?

អ៊ូមៈ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ!

ធីតាៈ បច្ចុប្បន្ននៅណារស់នៅស្រុកភូមិហ្នឹងដដែលទេ?

អ៊ូមៈ នៅហ្នឹងដដែលទេ!

ធីតាៈ គេអត់មានដូរទីតាំងភូមិទេ?

អ៊ូមៈ អត់ទេ!

ធីតាៈ មុនសម័យខ្មែរក្រហមអ៊ំធ្វើគេខ្លះនៅភូមិនេះ?

អ៊ូមៈ មុនខ្មែរក្រហម?

ធីតាៈ ចា៎!

អ៊ូមៈ ខ្ញុំអត់មានធ្វើអីទេ ធ្វើតែស្រែធ្វើចំការហ្នឹង!

ធីតាៈ អត់មានធ្លាប់ចូលរៀនចូលអីទេ?

អ៊ូមៈ អត់ទេ! ខ្ញុំអត់ចេះអក្សរណា៎!

ធីតាៈ ចុះប្ដីអ៊ំធ្វើអីគេ?

អ៊ូមៈ ប្តីខ្ញុំអត់ធ្វើអីទេ!

ធីតាៈ ឈ្មោះអីគេប្តី?

អ៊ូមៈ ឈ្មោះតាសួយ!

ធីតាៈ អាយុប៉ុន្មាន?

អ៊ូមៈ ឆ្នាំច មិនដឹងប៉ុន្មានទេ? ឆ្នាំចប្រហែលជា៦៥,៦៦ហើយដឹង!

ធីតាៈ ឥលូវគាត់នៅអត់?

អ៊ូមៈ គាត់រត់កាលសម័យខ្មែរក្រហម!

ធីតាៈ គាត់រត់?

អ៊ូមៈ ហ្នឹងអើយ!

ធីតាៈ ម៉េចបានរត់?

អ៊ូមៈ ចុះគេរត់គ្រប់គ្នា គ្មានអ្នកណានៅទេ!

ធីតាៈ ចុះដូចទីតាំងនៅនេះដំបូងគេធ្វើអីខ្លះទៅ ភូមិហ្នឹងកាលឌុចនៅគេធ្វើអីខ្លះទៅ?

អ៊ូមៈ កាលតាឌុចនៅនេះអត់មានធ្វើអីទេ!

ធីតាៈ អញ្ចឹង?

អ៊ូមៈ អត់មានខ្មែរក្រហមខ្មែរអីផង!

ធីតាៈ កាលឆ្នាំ៧១អ៊ំធ្វើអីគេ?

អ៊ូមៈ ខ្ញុំមិនចាំទេ!

ធីតាៈ អត់ចាំទេ?

អ៊ូមៈ ហ្នឹងអើយ ភ្លេចមុខភ្លេចក្រោយ!

ធីតាៈ អ៊ំអត់ចាំហ្មង?

អ៊ូមៈ ហ្នឹងអើយព្រោះអត់មានបានរៀនបានសូត្រអីទេ!

ធីតាៈ អត់បានទៅរៀនទៅអីទេ?

អ៊ូមៈ អត់បានរៀនទេ!

ធីតាៈ ចុះកាលសម័យលន់ នល់ធ្វើអីគេ?

អ៊ូមៈ កាលសម័យលន់ នល់ បងប្អូនច្រើន ហើយឪខ្ញុំគាត់ឈឺពោះហើយឲ្យខ្ញុំទៅភ្ជួររាស់អញ្ចឹងណា៎!

ធីតាៈ សម័យលន់ នល់អ៊ំរស់នៅហ្នឹងមែន?

អ៊ូមៈ រស់នៅហ្នឹងឯង!

ធីតាៈ  រស់នៅហ្នឹងធ្វើអីគេខ្លះ?

អ៊ូមៈ  គ្មានធ្វើអីទេធ្វើតែស្រែហ្នឹង!

ធីតាៈ  ចុះក្រៅពីការងារស្រែ?

អ៊ូមៈ  ក្រៅពីធ្វើស្រែដាក់កូននាងត្បាញសូត្រត្បាញអីហ្នឹង!

ធីតាៈ  ធ្វើកូននាង?

អ៊ូមៈ  ធ្វើកូននាងដាក់ត្បាញធ្វើកន្សែងធ្វើអីហ្នឹង!

ធីតាៈ  សម័យលន់ នល់?

អ៊ូមៈ  សម័យលន់ នល់!

ធីតាៈ  ហើយបន្ទាប់ពីហ្នឹងម៉ោធ្វើអីទៀត?

អ៊ូមៈ  បើខែធ្វើស្រែធ្វើស្រែទៅ ហើយដាក់កូននាងអញ្ចឹងទៅ។

ធីតាៈ  ចុះកាលសម័យហ្នឹងមានសកម្មភាពអីគេទេនៅក្នុងភូមិហ្នឹង ហើយគ្រួសារអីរស់នៅជួបជុំគ្នាទេ?

អ៊ូមៈ  កាលសម័យនោះនៅជុំគ្នា!

ធីតាៈ  ប៉ុន្មានគ្រួសារ?

អ៊ូមៈ  ២គ្រួសារ!

ធីតាៈ  ២គ្រួសារ?

អ៊ូមៈ  ចា៎!

ធីតាៈ  អ៊ំមានបងប្អូនប៉ុន្មាននាក់កាលសម័យនោះ?

អ៊ូមៈ  បងប្អូនខ្ញុំច្រើនណាស់ កាលសម័យនោះងាប់អស់៤នាក់ បងប្អូនខ្ញុំ១២នាក់។

ធីតាៈ  ចុះដូចប្ដីអ៊ំធ្វើអីគេកាលសម័យលន់ នល់?

អ៊ូមៈ  កាលសម័យលន់ នល់គាត់អត់បានធ្វើអីទេ!

ធីតាៈ  ប្ដីណា៎?

អ៊ូមៈ  ហ្នឹងអើយ!

ធីតាៈ  អត់បានធ្វើអីទេ?

អ៊ូមៈ  ធ្វើតែស្រែហ្នឹង!

ធីតាៈ  គាត់អត់មានចូលបដិវត្តន៍ចូលអីទេ?

អ៊ូមៈ  អត់ទេ! អាបដិវត្តន៍ហ្នឹងគេជម្លៀសគាត់ឲ្យទៅធ្វើស្រែ រត់អីរត់កាលនោះ ខ្ញុំមិនសូវចាំអីទេ កាលសម័យនោះ។

ធីតាៈ ភ្លេចអស់ហើយ!

អ៊ុំមៈ សម័យខែនេះឆ្នាំនេះគេរត់ ហើយយួន!

ធីតាៈ អត់ទាន់ទេ ខ្ញុំចង់និយាយកាលសម័យខ្មែរក្រហមសិន និយាយសម័យ៧៤,៧៣អីហ្នឹងអ៊ំធ្វើអីគេ?

អ៊ុំមៈ កាលហ្នឹង៧០ប៉ុន្មានទេរត់ទៅនេះហើយរត់ទៅដល់ភូមិទ្រាស ទៅដេកនោះបានពីរយប់ ហើយយើងយកអង្ករស៊ីតាមផ្លូវ ដល់ហើយគេឲ្យទៅនោះទៀតគេឲ្យទៅទាំងថ្ងៃ កាលសម័យខ្មែរក្រហម ហើយទៅដល់ភូមិអីទេគេឲ្យសម្រាកនៅនោះមួយយប់ ដល់សម្រាកមួយយប់ពេលរាងថ្ងៃបន្តិចគេបញ្ជូនទៅទៀត បញ្ជូនទៅទៀតទៅលង់ពួកស្វាយបានពីរខែរត់ទៅជួយប្រូតគេ គេឲ្យទៅជួយប្រូតគេ ដល់ពេលយប់ឡើងគេនាំចេញពីនេះទៅខាងកើតស្រុកនេះឯងទៅថ្នល់ដាច់ទៅដេកតាមផ្លូវហ្នឹងឯង យកឯងទៅដល់ថ្នល់ដាច់ហ្នឹង!

ធីតាៈ គេហៅអីគេអាហ្នឹង?

អ៊ុំមៈ គេហៅខ្មែរក្រហម!

ធីតាៈ គេទុកនៅកន្លែងអីគេ?

អ៊ុំមៈ គេទុកនៅកន្លែងអាងថ្នល់ដាច់ណា៎! គេទុកនៅហ្នឹង ហើយគេហៅប្រុសម៉ោប្រជុំនៅហ្នឹង ។

ធីតាៈ ហៅពួកប្រុសៗ?

អ៊ុំមៈ ហ្នឹងហើយ!

ធីតាៈ ខាងណាអ្នកហៅ?

អ៊ុំមៈ ខ្មែរក្រហម! ហៅម៉ោប្រជុំ

ធីតាៈ ប្រជុំហ្នឹងអ៊ំនៅហ្នឹងដែរមែន?

អ៊ុំមៈ ខ្ញុំអត់មានបានប្រជុំហ្នឹងគេទេ!

ធីតាៈ តែមានប៉ុន្មាននាក់ទៅដែលប្រជុំនៅហ្នឹង?

អ៊ុំមៈ ប្រជុំនៅនោះមានប្រុសប្រហែលជា៨នាក់! គេហៅម៉ោធ្វើជម្រក!

ធីតាៈ ធ្វើជម្រកអីគេ?

អ៊ុំមៈ ដូចជម្រកស្រូវយើងនេះណា! គេវ៉ៃជញ្ជាំងជិតហើយគេយកម៉ោដាក់ក្នុងរូងហ្នឹងទាំងអស់ គេយករទេះម៉ោពីរបីៗហ្នឹងស្រាប់តែប៉ាវ៉ាចូលម៉ោ ។

ធីតាៈ ប៉ាវ៉ាហ្នឹងឆ្នាំប៉ុន្មាន?

អ៊ុំមៈ ខ្ញុំភ្លេចហើយមិនដឹងឆ្នាំប៉ុន្មានទេ!

ធីតាៈ  អ៊ំអាចរកនឹកបានទេថាប៉ាវ៉ាចូលឆ្នាំប៉ុន្មាន?

អ៊ូមៈ  នឹកមិនឃើញទេ! ពេលប៉ាវ៉ាចូលម៉ោហ្នឹងគេចេញអស់ ។

ធីតាៈ  ចុះកាលសម័យខ្មែរក្រហមគេជម្លៀសអ៊ំទៅខាងណា?

អ៊ូមៈ  គេជម្លៀសទៅខាងនោះឯង!

ធីតាៈ  គេជម្លៀសទៅភូមិថ្មីហ្នឹង?

អ៊ូមៈ  ទៅភូមិទ្រាសទៅដេកបាន២យប់  ដល់ដេកបាន២យប់គេឲ្យខ្ញុំទៅប្រាំងនៅអូរតាម៉េងនៅទំនប់នោះ ដល់នេះទៅសភាពការណ៍ដូចថាមិនស្រួកគេយកឯងម៉ោទាំងថ្ងៃម៉ោច្រូត ដល់ពេលហើយយកឯងចេញទៅទាំងថ្ងៃ ដល់ហើយគ្រាប់កាំភ្លើងបាញ់ប៉ូងប៉ាំង១!

ធីតាៈ  គ្រាប់កាំភ្លើងបាញ់ពីខាងណាម៉ោវិញ?

អ៊ូមៈ  បាញ់តាមរទេះ វាបាញ់ពីក្រោយរទេះដើម្បីឲ្យយើងបរឲ្យលឿនណា៎!

ធីតាៈ  ខាងណាអ្នកបាញ់?

អ៊ូមៈ  ខាងខ្មែរក្រហម!

ធីតាៈ  ខាងខ្មែរក្រហម?

អ៊ូមៈ  ហ្នឹងអើយ!

ធីតាៈ  ហើយកាលហ្នឹងរទេះមានប៉ុន្មានដែលជម្លៀសទៅហ្នឹង?

អ៊ូមៈ  កាលហ្នឹងរទេះច្រើនណាស់!

ធីតាៈ  គិតទៅប៉ុន្មានគ្រួសារដែលជម្លៀសទៅភូមិទ្រាសហ្នឹង!

អ៊ូមៈ  មិនដឹងប៉ុន្មានគ្រួសារ

ធីតាៈ  ចេញពីសាលារៀន..?

អ៊ូមៈ  ចេញពីសាលារៀនម៉ោនេះ!

ធីតាៈ  សាលារៀនចេញពីនេះទៅ ទៅណាវិញ?

អ៊ូមៈ  សាលារៀនទៅនេះ កាលហ្នឹងរទេះប៉ុន្មានរយកាលនោះបើគ្រប់គ្រួសារអញ្ចឹង!

ធីតាៈ  ស្រីប្រុសទាំងចាស់ទាំងក្មេងអីទៅទាំងអស់គ្នាហ្មង?

អ៊ូមៈ  ទៅទាំងអស់! ពេលទៅដល់នោះទៅដេកហើយច្រូត  ដល់ហើយសភាពការណ៍វាមិនស្រួលវាហៅឯងទៅច្រូត ហើយវាបញ្ជូនទៅនោះទៀត ហើយវាដេញបាញ់តាមរទេះ ហើយកាលនោះមានកូនតាមរទេះវែកដងអីដង វែកកូនម៉ោតាមរទេះព្រោះខ្លាចត្រូវគ្រាប់គេបាញ់ណា៎ ខាងនោះ

ក៏បាញ់ខាងនេះក៏បាញ់ ដល់ពេលរត់គេថាសម្រាកនៅទីនេះសិនហើយដើម្បីឲ្យបាត់ហត់សិន ដល់ហើយក៏សម្រាកទៅ ។

ធីតាៈ ចុះកាលទៅហ្នឹងយកបានអីទៅខ្លះឥវ៉ាន់អីៗហ្នឹង?

អ៊ូមៈ យកបាន! នែ៎អាមួយដែលកាន់នៅភូមិផ្តាំឈ្មោះអា គក!

ធីតាៈ ឈ្មោះ គក?

អ៊ូមៈ ចា៎! វាបាញ់នៅភូមិនេះ វាហៅទៅវាធ្វើការជុំគ្នា មិនដឹងរឿងអីវាហៅទៅឲ្យធ្វើម្ហូបធ្វើអីកន្លែងឃ្លាំងអង្ករគេនៅកន្លែងសាលារៀនហ្នឹងឯង! ទៅធ្វើម្ហូបធ្វើអី ជួនកាលអាអ្នកខ្លះដែលខ្លាចវាទៅដើររកស្លឹកទ្រេល ស្លឹកកន្ទឹម ហើយមានម្នាក់បានចូលអនុបាត់ឈ្មោះ គ្រិន ។

ធីតាៈ គាត់ហ្នឹងម៉េច?

អ៊ូមៈ គាត់ធ្វើការជុំគ្នានៅនោះឯង ហើយគេយកគាត់ទៅបាញ់ចោល បាញ់ចោលភ្លាមមិនដឹងកើតផុះស្អីមិនដឹងអ្នកណាម៉ោពីណាមិនដឹង ស្រាប់តែដេញអាគកនោះ ដេញបាញ់អាគកនោះ!

ធីតាៈ អ៎! អ្នកដែលគ្រប់គ្រងនោះភូមិនោះមែន?

អ៊ូមៈ ហ្នឹងអើយ!

ធីតាៈ គាត់មេសហករណ៍ឬកងឈ្លប?

អ៊ូមៈ មិនមែនកងឈ្លបទេ!

ធីតាៈ មេសហករណ៍?

អ៊ូមៈ មេសហករណ៍!

ធីតាៈ មេសហករណ៍នៅភូមិដែលអ៊ំរស់នៅហ្នឹងមែន?

អ៊ូមៈ ហ្នឹងអើយ!

ធីតាៈ ហេតុអីបានជាគេបាញ់គាត់?

អ៊ូមៈ ចុះបើវាបាញ់អ្នកស្រុកនៅនេះ!

ធីតាៈ ស្លាប់៥នាក់មែន?

អ៊ូមៈ ស្លាប់តែពីរនាក់ទេ ហើយពេលដែលវាបាញ់ភ្លាមទៅដឹងតែកងឈ្លបម៉ោពីណាទេដេញបាញ់អានោះទៅ និយាយៗទៅបាញ់ងាប់នៅស្រុក ។

ធីតាៈ ចុះអ៊ំពេលដែលគេបាញ់អញ្ចឹងអ៊ំនៅខាងណាដែរ?

អ៊ូមៈ ខ្ញុំនៅក្នុងភូមិនេះឯង!

ធីតាៈ នៅភូមិហ្នឹងអត់រត់ទៅណាទេ?

អ៊ូម៖ អត់មានបានរត់ទៅណាទេ!

ធីតា៖ ម៉េចអញ្ចឹង?

អ៊ូម៖ ស្អែកឡើង ខានស្អែកឡើងគេយកទៅនេះ!

ធីតា៖ យកទៅណា?

អ៊ូម៖ យកទៅស្រុកទ្រាស ទៅដល់ថ្មពួកហើយវាឲ្យយើងបកម៉ោវិញទៅដេកនៅវត្តថ្មពួកមួយយប់ ហើយទៅលេងបងប្អូនវាឲ្យអង្ករម៉ោស៊ី ដល់ពេលបកម៉ោវិញម៉ោនៅគោកស្វាយ នៅហ្នឹងបាន បានអង្ករស៊ីហ្នឹង បានអង្ករមួយបោយ អ្នកណាគ្រួសារច្រើនបានមួយបោយធំ ដល់ពេលយប់ឡើងគេឲ្យចេញទៅនៅទំនប់នោះណាដែលខ្ញុំនិយាយនោះ ដល់ពេលទៅនៅទំនប់នោះគេហៅប្រុសទៅធ្វើការ ទាំងស្រីទាំងចាស់ក្មេងគេហៅ ហៅបានប៉ុន្មានគេឈប់ហៅ ដល់ឈប់ហៅខ្ញុំចុះម៉ោនេះ ដល់ហើយពួកយួនចូលម៉ោទៅ ហើយប៉ាវ៉ាម៉ោពីនោះបែកខ្មែរក្រហមអស់ក៏យួនចុះម៉ោបានខ្ញុំចូលស្រុក។

ធីតា៖ អ៊ីខ្ញុំចង់ឲ្យអ៊ីរៀបរាប់ឲ្យបានក្បោះក្បាយបន្តិច ដូចថាអ៊ីនៅវត្តថ្មពួកបានមួយយប់ហ្នឹង កន្លែងវត្តហ្នឹងម៉េចបានគេយកទៅដាក់នៅហ្នឹង?

អ៊ូម៖ កន្លែងវត្តនោះអត់មានលោកមានអីទេ ពួកខ្មែរក្រហមគេយកខ្ញុំទៅដាក់នៅនោះ ស្រុកគេនោះអត់មានមនុស្សទេមិនដឹងចេញទៅណាអស់ទេ។

ធីតា៖ យកទៅដាក់នៅស្រុកថ្មពួកហ្នឹងអត់មានមនុស្សនៅវិញ?

អ៊ូម៖ ស្រុកគេហ្នឹងវាអត់មានមនុស្សនៅទេ នៅភូមិគេហ្នឹងមិនដឹងថាពួកគេទៅខាងណា!

ធីតា៖ អញ្ចឹង?

អ៊ូម៖ ហើយនៅវត្តក៏មិនមានលោកមានអី!

ធីតា៖ អត់មានលោកមានអីទេ?

អ៊ូម៖ អត់មានទេ គេយកស្រុកខ្ញុំនេះទៅដាក់នៅនោះហើយដេកបានមួយយប់បានម៉ោទីនេះវិញ ម៉ោនៅនេះបានច្រូត បានច្រូតបានអង្ករស៊ីបានអី ហើយបានទៅអាងថ្នល់ដែក!

ធីតា៖ កន្លែងហ្នឹងគេដាក់អីគេអាងថ្នល់ដាច់ហ្នឹង?

អ៊ូម៖ អត់មានដាក់អីទេ! គេហៅប្រាសាទ!

ធីតា៖ ប្រាសាទថ្នល់ដាច់?

អ៊ូម៖ ហ្នឹងអើយ! គេយកទៅដាក់នៅនោះ!

ធីតា៖ ដាក់នៅហ្នឹងគេឲ្យធ្វើអីគេខ្លះ?

អ៊ូមៈ	អត់បានធ្វើអីទេ គ្រាន់តែហៅប្រុសៗឲ្យធ្វើការហ្នឹង!

ធីតាៈ	មានការបែងចែករស់នៅផ្សេងគ្នាទៅ?

អ៊ូមៈ	ហ្នឹងអើយ!

ធីតាៈ	បែងចែកម៉េចទៅ អ៊ំធ្វើការអីខ្លះ?

អ៊ូមៈ	អត់មានបានធ្វើការអីទេស្រីៗគ្រាន់តែឲ្យឃ្វាលគោ តែប្រុសៗគេយកទៅថ្មពួកមិនដឹងថាមានរឿងអីទេ!

ធីតាៈ	អញ្ចឹងមានថាគេបែងចែកប្រុសផ្សេងស្រីផ្សេង?

អ៊ូមៈ	ចា៎!

ធីតាៈ	ចុះអ៊ំធ្វើការហ្នឹងអត់មានមនុស្សប្រុសធ្វើការជាមួយទេឬ?

អ៊ូមៈ	អត់មានទេ!

ធីតាៈ	កាលហ្នឹងអាយុប៉ុន្មានដែលអ៊ំធ្វើការហ្នឹង?

អ៊ូមៈ	ខ្ញុំទើបអាយុ២៥ហ្នឹង! ខ្ញុំនៅយូហើយប្អូនខ្ញុំបានប្តីអស់ ខ្ញុំចេះតែធ្វើស្រែធ្វើចំការទៅ!

ធីតាៈ	ទៅទាំងអស់គ្នាឬក៏ម៉េច?

អ៊ូមៈ	ទៅទាំងគ្រួសារ!

ធីតាៈ	ទៅទាំងគ្រួសារ?

អ៊ូមៈ	ហ្នឹងអើយ!

ធីតាៈ	ប៉ុន្តែពេលបែងចែកការងារផ្សេងគ្នាទៅ!

អ៊ូមៈ	ហ្នឹងអើយ! អ្នកណាមានកន្លែងប្រូតកាត់គេទៅប្រូតទៅ ទៅប្រូតនៅភូមិថ្នល់ដាច់ហ្នឹងទៅគេយកយើងទៅដាក់នៅអាងនោះ ដល់ពេលទៅថ្នល់ដាច់នោះគេយកម៉ោទំនប់តាម៉េងវិញ ។

ធីតាៈ	ទំនប់អីគេ?

អ៊ូមៈ	ទំនប់តាម៉េង!

ធីតាៈ	ទំនប់តាម៉េងហ្នឹងយូនៅឬក៏ទើបតែកើតទេ?

អ៊ូមៈ	យូហើយតាំងពីសង្គមនោះ មិនមែនទំនប់ខ្មែរក្រហមទេ ទំនប់ពីបុរាណនោះ!

ធីតាៈ	កាលហ្នឹងអ៊ំធ្វើការនៅហ្នឹងមែន?

អ៊ូមៈ	ចា៎?

ធីតាៈ	និយាយថាកាលហ្នឹងថាអ៊ំធ្វើការនៅទំនប់តាម៉េងហ្នឹងមែន?

អ៊ូម៖ នៅទំនប់តាម៉េងហ្នឹងនៅដេកហ្នឹងបានប៉ុន្មានយប់ ហើយបានពួកប៉ាវ៉ាជួយ ពួកខ្មែរក្រហមគេយកម៉ោ!

ធីតា៖ ពួកខ្មែរក្រហមជម្លៀសទៅសម័យហ្នឹងនៅឆ្នាំប៉ុន្មាន?

អ៊ូម៖ អត់ចំនាំឆ្នាំបានទេ!

ធីតា៖ អត់ចាំបានហ្នង អត់មានចាំថា៧៥ឬ៧៦អីទេ?

អ៊ូម៖ ចាំមិនបានទេនាង!

ធីតា៖ ចុះប្ដីអ៊ំធ្វើអីគេ?

អ៊ូម៖ ធ្វើស្រែ!

ធីតា៖ អត់មានធ្វើអីផ្សេងទៀតទេ?

អ៊ូម៖ អត់ទេ!

ធីតា៖ គាត់ធ្លាប់ស្គាល់ឌុចស្គាល់អីទេ?

អ៊ូម៖ ទេគាត់មិនបាននៅនេះទេ!

ធីតា៖ ចុះអ៊ំពេលឌុចម៉ោអ៊ំដឹង?

អ៊ូម៖ ពេលតាឌុចម៉ោនៅធ្វើផ្ទះធ្វើសំបែងនៅហ្នឹង កាលនោះអត់ទាន់មានរោងចក្រអីទេ គាត់ដើរម៉ោលេង!

ធីតា៖ ឆ្នាំប៉ុន្មាន?

អ៊ូម៖ វាមិនចាំ!

ធីតា៖ អត់ចាំទេ?

អ៊ូម៖ មិនចាំទេ!

ធីតា៖ ចុះអ៊ំអ្វីដែលអ៊ំចាំជាងគេ?

អ៊ូម៖ មិនដឹងចាំអីទេ!

ធីតា៖ ចុះមានដែលឃើញគេសម្លាប់មនុស្សទេ?

អ៊ូម៖ មិនដែលឃើញទេ! ដឹងតែគេចាប់យកធ្វើទាហានធ្វើអីហ្នឹង!

ធីតា៖ ចុះអ៊ំអត់មានបានទៅត្រពាំងថ្មទេ?

អ៊ូម៖ ខ្ញុំទៅណាកើតបើខ្ញុំមានផ្ទៃពោះ!

ធីតា៖ កាលហ្នឹងកំពុងមានផ្ទៃពោះ?

អ៊ូម៖ ចា៎!

ធីតាៈ  កាលហ្នឹងកូនប៉ុន្មានទៅ?

អ៊ូមៈ  កូន២នាក់ ៣ទាំងនៅក្នុងពោះហ្នឹង! កាលប្ដីរត់នោះខ្ញុំទើបតែបានពីរបីខែហ្នឹង ដល់ទៅធ្វើចល័ត នៅនោះរត់ទៅ ខ្ញុំមានផ្ទៃពោះគេមិនឲ្យទៅនៅភូមិណាទេ ដល់ហើយគេចល័តទៅនៅភូមិត្រាកក់ ស្រុកអំពិលស្រុកអីនោះ ហើយគេឲ្យទៅនៅតាមចំការណា៎ បើសិនចល័តទៅនោះងាប់អស់ ។

ធីតា  នៅចំការអីគេ?

អ៊ូមៈ  នៅតាមចំការខាងកើតផ្លូវ ចំការដែលគេដាំដំឡូងដាំអីណា៎ គេឲ្យទៅនៅភូមិទ្រាសភូមិអីគេឲ្យទៅ នៅតាមចំការរបស់គេណា៎!

ធីតាៈ  ចុះពេលដែលចល័តហ្នឹងអ៊ំធ្វើការងារអីគេខ្លះ?

អ៊ូមៈ  ខ្ញុំអត់មានបានចល័តទៅទេ!

ធីតាៈ  អត់ចល័តទេនៅក្នុងស្រុកហ្នឹងហ្នង?

អ៊ូមៈ  ចា៎!

ធីតាៈ  ចុះអ៊ំថាទៅភូមិទ្រាសនោះ!

អ៊ូមៈ  ទេអានោះរត់ទៅភូមិទ្រាសនោះ!

ធីតាៈ  ចុះអ្នកណាគេអ្នកគ្រប់គ្រងនៅហ្នឹង ហើយការរស់នៅហ្នឹងយ៉ាងម៉េចដែរ?

អ៊ូមៈ  អាគកដែលគេបាញ់ងាប់ហ្នឹង!

ធីតាៈ  អញ្ចឹង បាញ់នៅឆ្នាំណាដែរ?

អ៊ូមៈ  ចាំមិនបានទេ!

ធីតាៈ  មានចាំថាខែប្រាំងឬក៏ខែច្រូតខែអី!

អ៊ូមៈ  ដឹងតែខែច្រូតតែមិនដឹងថាខែអីទេ!

ធីតាៈ  អត់ដឹងទេ?

អ៊ូមៈ  អត់!

ធីតាៈ  អ៊ំអត់សួរចាំទេ?

អ៊ូមៈ  ហ្នឹងអើយ!

ធីតាៈ  ចុះកាល៧៦អ៊ំធ្វើអីគេដែរ?

អ៊ូមៈ  ក្រងស្បូវ!

ធីតាៈ  ក្រងស្បូវយ៉ាងម៉េចទៅ?

អ៊ូមៈ  ក្រងស្បូវសម្រាប់ប្រក់នោះ!

ធីតាៈ មួយថ្ងៃគេឲ្យធ្វើឲ្យបានប៉ុន្មាន?

អ៊ូមៈ ស្រេចតែយើងណា៎ យើងធ្វើបានប៉ុន្មានក៏បាន! កាលហ្នឹងឯងមានផ្ទៃពោះគេឲ្យនៅក្រុង!

ធីតាៈ មានផ្ទៃពោះ?

អ៊ូមៈ ហ្នឹងអើយ!

ធីតាៈ ហើយអ្នកផ្សេងទៀតទៅធ្វើការទៅផ្សេងទៅ!

អ៊ូមៈ អ្នកណាដែលយ៉ាប់ៗគេឲ្យនៅក្រុងស្បូវទៅ ហើយទៅស៊ីបាយរួម!

ធីតាៈ បាយរួម?

អ៊ូមៈ ហ្នឹងអើយ! មួយក្រុម៣០គ្រួសារ! មួយក្រុម៣០គ្រួសារហើយឲ្យ៩គំប៉ុងណានាង!

ធីតាៈ កាលហ្នឹងប៉ះចំខែច្រូតកាលឆ្នាំ៧៦ហ្នឹង?

អ៊ូមៈ ចា៎! កាលហ្នឹងច្រូតស្រូវកណ្ដាល ខ្ញុំវាមិនសូវចាំឆ្នាំចាំខែ ហើយប្ដីទៅក៏មិនដឹងទៅឆ្នាំណា គេចល័តនោះគេទៅបាត់ក៏មិនដឹងទៅណា កូនគាត់វាតូចៗគេសួរក គេម៉ោគេសួថាឯណាពួកខ្ញុំមិនឃើញម៉ោ កាលម៉ាជិនាន់គាត់ទៅប៉ុន្មាននាក់ ។

ធីតាៈ ចុះកាល៧៦ហ្នឹងគេឲ្យក្រុងស្បូវក្រុងអីហ្នឹង អ្នកណាគេជាអ្នកគ្រប់គ្រងថែមទៀត មានតែ គក ហ្នឹងមួយទេ?

អ៊ូមៈ ទេមានទៀតតែខ្ញុំវាមិនស្គាល់ឈ្មោះទេ ស្គាល់តែអាគកដែលគេបាញ់សម្លាប់នោះហ្នឹង!

ធីតាៈ ដេញម៉េច?

អ៊ូមៈ ដេញបាញ់! ស្រុកខ្ញុំសម្លាប់អស់ប៉ុន្មាននាក់នោះ វាដេញបាញ់អាកន្លែងឃ្លាំងអង្ករហ្នឹង!

ធីតាៈ កន្លែងសាលារៀនហ្នឹង?

អ៊ូមៈ ហ្នឹងអើយ! គេដាក់ឃ្លាំងអង្ករនៅហ្នឹង!

ធីតាៈ អញ្ចឹងមានន័យថាកន្លែងសាលារៀនហ្នឹងគេយកធ្វើជាកន្លែងឃ្លាំងអង្ករ?

អ៊ូមៈ ហ្នឹងអើយឃ្លាំងអង្ករគេនៅនោះឯង!

ធីតាៈ សាលារៀនអីគេ សាលារៀនផ្គាំហ្នឹងមែន?

អ៊ូមៈ ហ្នឹងអើយ!

ធីតាៈ កាលហ្នឹងឃ្លាំងអង្ករហ្នឹងដាក់ស្រូវប៉ុន្មានទៅ ស្រូវច្រើនទេ?

អ៊ូមៈ កាលហ្នឹងគេដាក់ជង្រុក កាលហ្នឹងជង្រុកវាធំណាស់ ហើយមិនដឹងថាវាយកទៅណាទេ!

ធីតាៈ ចុះអ៊ីមានដឹងថាគេយកសាលារៀនហ្នឹងតាំងពីឆ្នាំណាទេ ឆ្នាំណាពេលដែលគេយកដាក់ជាឃ្លាំង អង្ករហ្នឹង?

អ៊ូម: មិនដឹងឆ្នាំណាឆ្នាំណីទេ!

ធីតា: តាំងពីសង្គមឬកាលសម័យខ្មែរក្រហម?

អ៊ូម: ទើបតែសម័យខ្មែរក្រហមនេះឯង បើកាលសម័យសង្គមគេរៀន ដល់សម័យខ្មែរក្រហមនេះគេយកធ្វើឃ្លាំងអង្ករ!

ធីតា: គេយកធ្វើឃ្លាំងអង្ករហ្នង?

អ៊ូម: ហ្នឹងអើយ!

ធីតា: ហើយកន្លែងឃ្លាំងអង្ករហ្នឹងអ្នកណាគេអ្នកគ្រប់គ្រង?

អ៊ូម: កាលហ្នឹងមិនដឹងអ្នកណាទេ ដូចជាតាចិអីទេ?

ធីតា: រស់នៅស្រុកភូមិអីគេដែរ?

អ៊ូម: គាត់នៅភូមិបេង!

ធីតា: ឃុំ?

អ៊ូម: ឃុំបេង!

ធីតា: ស្រុក?

អ៊ូម: ស្រុកបេង ខេត្តឧត្តមានជ័យ!

ធីតា: ហើយអ៊ំដូចថាសាលារៀនហ្នឹងគេយកទៅដាក់ធ្វើជាឃ្លាំងអង្ករហ្នឹង ពេលគេប្រមូលស្រូវបានគេយកទៅដាក់នៅហ្នឹងហ្នង?

អ៊ូម: ស្រូវប្រូតបានគេយកទៅដាក់នៅជង្រុកខាងត្បូងនោះ!

ធីតា: នៅកន្លែងណាវិញ?

អ៊ូម: នៅកន្លែងមណ្ឌលណា! មណ្ឌលពេទ្យនៅចុងស្រុកណ៎!

ធីតា: នៅចុងស្រុកណាទៅ?

អ៊ូម: មើលមិនឃើញទេនៅខាងលិចផ្លូវណ៎!

ធីតា: ប្រហែលប៉ុន្មានទៅទំហំនៅកន្លែងឃ្លាំងអង្ករហ្នឹង?

អ៊ូម: គេធ្វើវែង!

ធីតា: អ៊ំអាចស្មានបានទេថាបណ្តោយប៉ុន្មានម៉ែត ទទឹងប៉ុន្មានម៉ែតអ៊ំដឹងទេ?

អ៊ូម: បណ្តោយប្រហែលជា៥០ម៉ែត!

ធីតា: ចុះទទឹងប៉ុន្មាន ហើយទំហំវាសរុបទៅប៉ុន្មានម៉ែតទៅ?

អ៊ូម: មិនដឹងទេ!

ធីតាៈ ចុះអុំអត់មានបានរៀនបានអីទេ?

អ៊ុំមៈ អត់មានបានរៀនទេ ប្អូនបានរៀនបានអីខ្លះ!

ធីតាៈ ចុះថានៅបែកគ្នាតើ ម៉េចក៏ដឹងម្ល៉េះ?

អ៊ុំមៈ ប្អូនខ្ញុំកាលហ្នឹងខ្ញុំមានទាន់បានប្ដីណា៎!

ធីតាៈ ខ្ញុំចង់ឲ្យអុំរៀបរាប់ថាកាលសម័យខ្មែរក្រហមហ្នឹងអុំធ្វើអីខ្លះ ហើយម៉េចខ្លះអីខ្លះអញ្ចឹងណាអុំ?

អ៊ុំមៈ អត់មានបានស៊ីអត់មានបានដើរទៅណាទេ! ហើយស្ងួតក៏អត់មានបានទៅដែរ!

ធីតាៈ អញ្ចឹងគ្រាន់តែក្រងស្បូវមួយមុខទេ?

អ៊ុំមៈ ចា៎!

ធីតាៈ អង្គការខ្មែរក្រហមឲ្យចំណាយពេលឲ្យធ្វើមួយថ្ងៃឲ្យបានប៉ុន្មាន?

អ៊ុំមៈ គេអត់ដាក់កម្រិតទេ ស្រេចតែយើងធ្វើព្រោះយើងមានផ្ទៃពោះ អង្គុយយូវាហើមជើង ថ្ងៃណាខ្លះបាន១២ ហើយថ្ងៃណាខ្លះទៀតបាន១៥អញ្ចឹងទៅ ដល់ហើយគេឲ្យទៅនៅចំការដំឡូង ចំការអីនោះ ៗ

ធីតាៈ ចុះអ្នកដែលគ្រប់គ្រងឈ្មោះតាចិហ្នឹង ឈ្មោះតាចិ?

អ៊ុំមៈ តាចិ! គាត់បានប្រពន្ធនៅនេះហើយបានកូនមួយ!

ធីតាៈ គ្រប់គ្រងនៅហ្នឹងម៉េចដែរគាត់ ដូចថាកាចសាហាវទេ?

អ៊ុំមៈ ធម្មតាទេ គាត់មិនអ្នកកាចទេ!

ធីតាៈ ចុះកាលឆ្នាំ៧៧អុំធ្វើអីគេដែរ?

អ៊ុំមៈ កាល៧៧?

ធីតាៈ កាល៧៧ពេលអុំធ្វើការងារក្រងស្បូវហ្នឹងហើយមានការងារអីបន្ថែមទៀតទេ?

អ៊ុំមៈ ខ្ញុំមិនបានទៅប្រូតទៅកាត់ទៅចំការទៅអីហ្នឹងគេទេ យើងមានផ្ទៃពោះគេឲ្យយើងធ្វើការងារស្រាល!

ធីតាៈ គេឲ្យធ្វើការងារស្រាលនៅក្នុងភូមិ?

អ៊ុំមៈ កាលហ្នឹងគេឲ្យកិនស្រូវកិនអីនៅខាងជើងនោះ!

ធីតាៈ ជើងនៅខាងណា អាហ្នឹងទៅខាងណាវិញ?

អ៊ុំមៈ ខ្មែរក្រហមយកទៅ យកទៅថ្នួក!

ធីតាៈ ថ្នួក?

អ៊ុំមៈ ហ្នឹងអើយ! ទៅហ្នឹងកិនស្រូវបានពីរបីថ្ងៃយកអង្ករម៉ោបានប្រហែលជាកន្លះឡានហើយគេជម្លៀសដែលខ្ញុំនិយាយនោះឯង!

ធីតាៈ អញ្ចឹងអ៊ុំអត់មានផ្លាស់ប្តូរទេក្រៅតែពីការងាររប៉ុណ្ណឹង?

អ៊ុំមៈ អត់មានបានធ្វើអីទេ!

ធីតាៈ អត់មានផ្លាស់ទៅនៅខាងណាផ្សេងទេ?

អ៊ុំមៈ អត់មានទៅណាទៅណីផ្សេងទេ!

ធីតាៈ ឲ្យតែនៅហ្នឹងហ្មង?

អ៊ុំមៈ ហ្នឹងអើយ!

ធីតាៈ ទៅនៅភូមិទ្រាសហ្នឹង?

អ៊ុំមៈ ទៅនៅថ្នល់ដាច់!

ធីតាៈ ហើយប្រជាជនណានៅណាខ្លះដែលម៉ោរស់នៅហ្នឹង?

អ៊ុំមៈ នៅតាមភូមិទ្រាសភូមិអីហ្នឹង ហើយទៅដល់ភូមិស្វាយ!

ធីតាៈ ហ្នឹងអើយហើយមានប្រជាជនម៉ោពីខាងណាខ្លះដែលម៉ោរស់នៅហ្នឹង ដែលអ៊ុំទៅរស់នៅដែលខ្មែរក្រហមជម្លៀសទៅហ្នឹង?

អ៊ុំមៈ ទៅនៅភូមិទ្រាសប៉ុន្មានថ្ងៃទេ ហើយចេញទៅទៀត!

ធីតាៈ ចេញទៅខាងណាវិញ?

អ៊ុំមៈ ចេញទៅភូមិថ្មី!

ធីតាៈ ភូមិថ្មីហ្នឹងឃុំអីគេ?

អ៊ុំមៈ ខ្ញុំមិនសូវបានដឹងភូមិទេ!

ធីតាៈ ភូមិហ្នឹងគេទើបតែកើតប្អុក៏យូហើយ?

អ៊ុំមៈ តាំងពីសង្គមម៉ោនោះតែខ្ញុំវាមិនចាំ!

ធីតាៈ តាំងពីយូហើយមែនទេ?

អ៊ុំមៈ មិនដែលបានចាំភូមិនេះភូមិនោះ!

ធីតាៈ ចុះក្រៅពីភូមិថ្មីហ្នឹងធ្វើការងារអីគេខ្លះ?

អ៊ុំមៈ ក្រៅពីភូមិថ្មីហ្នឹងទៅដល់វត្តថ្មពួក ហើយគេឲ្យដេកនោះឯង ឲ្យដេកនោះតែមិនដឹងគេឲ្យធ្វើអីមានតែដាំបាយស៊ីហើយមើលគោមើលអីហ្នឹង!

ធីតាៈ ហើយទៅហ្នឹងទៅរហូតអញ្ចឹងហ្មង?

អ៊ូម: បកម៉ោនៅភូមិស្វាយ! បកពីវត្តថ្មពួកម៉ោនៅភូមិស្វាយនេះ បានតែជួយច្រូតស្រូវគេហើយ កិនអង្ករ ដល់ហើយដឹកចេញទៅ!

ធីតា: ចេញទៅអាងត្រពាំងថ្មមែន?

អ៊ូម: អត់ទេ!

ធីតា: អត់ទៅហ្នឹងទេ?

អ៊ូម: អត់ទេមានអាងត្រពាំងថ្មឯណា ទៅអន្លុងព្រីង!

ធីតា: អន្លុងព្រីង?

អ៊ូម: ចេញពីអន្លុងព្រីងទៅបានទៅដល់ថ្នល់ដែក ទៅដេកតាមផ្លូវមួយយប់សិនដល់ព្រឹកឡើងបាន ក្រោកទៅទៀត ។

ធីតា: អញ្ចឹង៧៧ហ្នឹងនៅតែក្នុងភូមិហ្នឹងអត់មានធ្វើអីផ្សេងក្រៅពីហ្នឹងទេឬ ចុះកាលអ៊ំសម្រាលកូននៅ ឆ្នាំណាទៅ?

អ៊ូម: ភ្លេចអស់ហើយ!

ធីតា: ចុះកាលឆ្នាំ៧៧ហ្នឹងមានដែលបានម៉ោជួបជុំគ្រួសារទេ ខ្មែរក្រហមមានដែលឲ្យម៉ោជួបមុខគ្នាទេ មានដែលម៉ោជួបមុខគ្នាទេ?

អ៊ូម: អត់ទេ!

ធីតា: ៧៧ហ្នឹងធ្វើអីគេខ្លះក្រៅពីការងារនៅភូមិហ្នឹងថ្នល់ដាច់ហ្នឹងដូចថាច្រូតអីហ្នឹង ដូចថាផ្លាស់ឲ្យទៅ រស់នៅផ្សេងទៀតអីអត់ទេឬ?

អ៊ូម: អត់បានធ្វើអីទេ!

ធីតា: តែអ៊ំអ្នកគ្រប់គ្រងនៅក្នុងឆ្នាំហ្នឹងទេ បើផ្លាស់ភូមិរហូតអញ្ចឹង?

អ៊ូម: អត់ចាំទេ!

ធីតា: អញ្ចឹងឆ្នាំណាដែលអ៊ំចាំ ពេលអ៊ំឃើញខុច?

អ៊ូម: ពេលឃើញតាខុចហ្នឹងមិនដឹងឆ្នាំណាទេ គ្រាន់តែឃើញគាត់ម៉ោហ្នឹងគាត់ដើរលេង!

ធីតា: ពេលឆ្នាំ៧៧,៧៨,៧៩ហ្នឹងនៅតែរស់នៅក្នុងភូមិហ្នឹងរហូតហ្នង?

អ៊ូម: ចា៎!

ធីតា: ធ្វើតែការងារនៅហ្នឹង?

អ៊ូម: ចា៎!

ធីតា: ចុះពេលវៀតណាមចូលម៉ោម៉េចដឹងថាបែក?

អ៊ូម: អាបែកហ្នឹងមិនដឹងឆ្នាំណា?

ធីតា: ឆ្នាំ៧៩ វៀតណាមចូលម៉ោអីរស់នៅណា!

អ៊ូម: នៅតាម៉េន!

ធីតា: នៅតាម៉េនហ្នឹង?

អ៊ូម: ហ្នឹងអើយ! អាហ្នឹងពេលយួនចូលអញ្ចេះ!ៗ

ធីតា: យួនចូលពីខាងណាម៉ោវិញ?

អ៊ូម: យួនចូលម៉ោក្នុងភូមិនេះឯង ពួកខ្ញុំនៅតាម៉េនដែលម៉ោពីថ្មល់ដែកម៉ោនោះ យួនគេទៅពីនេះ ប៉ាកគេម៉ោពីខាងនោះ តែមិនដឹងឆ្នាំអីទេ !

ធីតា: ប៉ាកអាចចូលឆ្នាំ៨០អីហ្នឹង!

អ៊ូម: ប្រជាជនម៉ោ!

ធីតា: អុំត្រលប់ម៉ោភូមិនេះវិញ?

អ៊ូម: ត្រលប់ម៉ោភូមិនេះវិញ!

ធីតា: ត្រលប់ម៉ោភូមិនេះវិញនៅផ្ទះអុំកាលហ្នឹងអុំនៅណា?

អ៊ូម: នៅនេះឯង!

ធីតា: នៅហ្នឹង?

អ៊ូម: ចាំ!

ធីតា: ហើយពេលម៉ោហ្នឹងផ្ទះហ្នឹងមានសភាពយ៉ាងម៉េចដែរ សកម្មភាពក្នុងផ្ទះហ្នឹងយ៉ាងម៉េចដែរ?

អ៊ូម: អត់មានអីទេ!

ធីតា: កន្លែងផ្ទះហ្នឹងគេយកធ្វើអីគេ?

អ៊ូម: អត់មានយកធ្វើអីទេ!

ធីតា: ហើយពេលត្រលប់ម៉ោវិញមានតែជនជាតិចាមទេ អត់មានជនជាតិចាមទេ?

អ៊ូម: មានតែវៀតណាមនឹងខ្មែរ វៀតណាមយករទេះយកប្រជាជនម៉ោហ្នឹង!

ធីតា: ហើយកាលហ្នឹងអុំម៉ោប៉ុន្មាននាក់ទៅ?

អ៊ូម: កាលហ្នឹងម៉ោតិចណាស់!

ធីតា: ប៉ុន្មានគ្រួសារអុំដែលត្រលប់ម៉ោវិញ?

អ៊ូម: កូនខ្ញុំតែពីនាក់ទេ ហើយក្រៅពីហ្នឹងសុទ្ធតែបងប្អូនខ្ញុំ!

ធីតាៈ អញ្ចឹងអ៊ំមេម៉ាយមែនទេ?

អ៊ូមៈ ខ្ញុំមេម៉ាយដែរ!

ធីតាៈ មេម៉ាយនៅឆ្នាំណា?

អ៊ូមៈ ខ្ញុំភ្លេចឆ្នាំពេលដែលប្តីរត់ វាមិនចាំ និយាយទៅវាមិនចំនាំហ្នឹង!

ធីតាៈ ចាំ!

អ៊ូមៈ កាលហ្នឹងតាពិនគេម៉ោ!

ធីតាៈ តាឌុចហ្នឹងមែន?

អ៊ូមៈ ហ្នឹងអើយ! កាលហ្នឹងនាយកសាលាគេកត់ឈ្មោះ!

ធីតាៈ គេកត់ឈ្មោះយ៉ាងម៉េច?

អ៊ូមៈ កត់ឈ្មោះដូចថាអ្នកណាកូនប៉ុន្មាននាក់ ហើយខ្ញុំមិនដឹងអីសោះ!

ធីតាៈ នាយកសាលាហ្នឹងម៉ោឆ្នាំណា?

អ៊ូមៈ ដូចថាគេម៉ោធ្វើការ ហើយគេប្រជុំ កាលហ្នឹងខ្ញុំមិនសូវចាំទេ បើនិយាយពីតាឌុចខ្ញុំមិនសូវចាំទេ និយាយពីឆ្នាំនេះឆ្នាំនោះ និយាយពីតាឌុចម៉ោនៅឆ្នាំនេះឆ្នាំនោះខ្ញុំមិនចាំទេ ។

ធីតាៈ ចុះអ៊ំអត់មានចាំថាតាឌុចម៉ោនៅឆ្នាំណាទេ?

អ៊ូមៈ អត់ដឹងទេ!

ធីតាៈ ប៉ុន្តែដឹងថាឌុចហ្នឹងធ្លាប់ម៉ោលេងជាមួយអ៊ំ?

អ៊ូមៈ ធ្លាប់ម៉ោជាមួយប្រពន្ធគាត់ម៉ោដើរលេង!

ធីតាៈ ធ្លាប់ម៉ោជាមួយប្រពន្ធគាត់ ប្រពន្ធគាត់ឈ្មោះអីគេ?

អ៊ូមៈ ឈ្មោះយាយម៉ៅ គេហៅយាយម៉ៅៗ!

ធីតាៈ ហើយធ្លាប់ទំនាក់ទំនងជាមួយអ៊ំដែរអត់?

អ៊ូមៈ មិនដែលបានទំនាក់ទំនងស្អីទេ ព្រោះគាត់ខ្មែរក្រហម!

ធីតាៈ កាលហ្នឹងអត់មានដឹងថាគាត់ជាខ្មែរក្រហមទេ?

អ៊ូមៈ មិនដឹងទេស្មានតែគាត់ជាអ្នកស្រុកធម្មតា!

ធីតាៈ អ្នកភូមិជាមួយគ្នាមែន?

អ៊ូមៈ ចាំ!

ធីតាៈ ហើយកាលហ្នឹងឌុចដើរម៉ោលេងនៅក្នុងភូមិហ្នឹងមែន?

អ៊ូមៈ ដើរលេងតាមផ្ទះនេះផ្ទះនោះ គាត់ដើរលេងព្រោះគាត់អផ្សុកគាត់ ។១

ធីតាៈ អ៊ំនិយាយអញ្ចឹងដូចថាឌុចម៉ោចូលនៅឆ្នាំ៩០ណា៎!

អ៊ូមៈ មិនដឹងទេ!

ធីតាៈ ពេលវៀតណាមចូលម៉ោឌុចនៅនេះឆ្នាំ៩០ រស់នៅស្រុកស្វាយចេកនេះ!

អ៊ូមៈ នៅនេះរួចបានគាត់ទៅនៅស្រុកស្វាយចេក កាលហ្នឹងគេចូលប្ដូរប្រពន្ធគាត់ បាញ់ប្រពន្ធគាត់!

ធីតាៈ ហ្នឹងអើយ! ហើយម៉េចបានចោរប្ដូរប្រពន្ធគាត់?

អ៊ូមៈ មិនដឹងទេ!

ធីតាៈ អត់ដឹងទេ?

អ៊ូមៈ អត់! ដល់ពេលប្រពន្ធគាត់ស្លាប់បានគាត់ទៅនៅស្រុកស្វាយចេក នាំកូននាំចៅទៅនៅស្វាយចេក!

ធីតាៈ ចុះអ៊ំហើយនឹងប្រពន្ធគាត់អត់មានដែលនិយាយទំនាក់ទំនងជាមួយគ្នាទេ?

អ៊ូមៈ អត់ទេ!

ធីតាៈ អត់ដែលហ្មង?

អ៊ូមៈ អត់! បើរឿងនិយាយលេងសើចជាមួយគ្នាអត់ដែលមានទេ!

ធីតាៈ មើលទៅអត្តចរិកគាត់យ៉ាងម៉េចដែរ ដូចថាពេលដែលគាត់និយាយម៉ោយ៉ាងម៉េចដែរ ហើយមនុស្សនៅក្នុងភូមិហ្នឹងយ៉ាងម៉េចដែរចូលចិត្តគាត់ឬអត់?

អ៊ូមៈ គេរាប់អានគាត់តើ គេនិយាយគ្នាទៅវិញទៅម៉ោ!

ធីតាៈ និយាយគ្នាទៅវិញទៅម៉ោ?

អ៊ូមៈ ហ្នឹងអើយ!

ធីតាៈ និយាយម៉េចខ្លះទៅនិយាយទៅវិញទៅម៉ោហ្នឹង

អ៊ូមៈ និយាយលេង!

ធីតាៈ និយាយអីគេខ្លះទៅលេងហ្នឹង?

អ៊ូមៈ ម៉េចចាំនាងអើយ!

ធីតាៈ គាត់ម៉ោលេងហ្នឹងម៉ោលេងរយៈពេលយូដែរ?

អ៊ូមៈ មិនដឹងទេ!

ធីតាៈ គាត់ម៉ោលេងញឹកទេ?

អ៊ូមៈ អត់ទេយូៗគាត់ម៉ោអង្គុយលេងមួយភ្លែតហើយគាត់ទៅវិញទៅ បន្តិចទៅផ្ទះនេះហើយបន្តិចទៅផ្ទះនោះ!

ធីតាៈ ឌុចដើរលេងតាមភូមិទាំងអស់ហ្នុង?

អ៊ូមៈ ហ្នឹងអើយ! មិនដល់ទីនោះទេ ត្រឹមមួយកំណាត់នេះទេ គាត់ដើរលេងមិនបាននិយាយអីទេ មានតែនិយាយលេងសើចអីផ្សេងៗ តែខ្ញុំមិនដឹងថាគាត់ខ្មែរក្រហម!

ធីតាៈ អញ្ចឹង?

អ៊ូមៈ ហ្នឹងអើយ! មិនដឹងអីទេស្មានតែគាត់ជនណាម៉ោស្នាក់អាស្រ័យនៅក្នុងភូមិនេះ!

ធីតាៈ ដើរលេងហ្នឹងពេលណាដែរ ពេលដែលគាត់ម៉ោលេងអំហ្នឹង ពេលព្រឹកឬក៏ពេលថ្ងៃ?

អ៊ូមៈ ថ្ងៃ គាត់ស៊ីបាយរួចគាត់ដើរលេង!

ធីតាៈ នៅក្នុងភូមិហ្នឹងអ្នកណាគេជិតដិតជាមួយឌុចជាងគេ?

អ៊ូមៈ មិនដឹងអ្នកណាជិតដិតបើមិនដែលដឹងផង!

ធីតាៈ អត់ដែលដឹងទេ?

អ៊ូមៈ ហ្នឹងអើយ! យូៗគាត់ម៉ោមួយដង គាត់ដើរទៅនេះទៅនោះ ហើយគាត់ត្រលប់ទៅវិញទៅ គាត់បានម៉ាស៊ីនគាត់មួយ!

ធីតាៈ ឌុចហ្នឹងមែន?

អ៊ូមៈ ចា៎!

ធីតាៈ ម៉ាស៊ីនអីគេ?

អ៊ូមៈ ខ្ញុំឮគេថាម៉ាស៊ីនកិនស្រូវ!

ធីតាៈ ហើយដែលធ្លាប់ទៅលេងផ្ទះគាត់វិញទេ?

អ៊ូមៈ ទេមិនដែលទេ!

ធីតាៈ ផ្ទះគាត់ពីហ្នឹងទៅហ្នឹងប៉ុន្មានទៅ?

អ៊ូមៈ ជិតរោងម៉ាស៊ីនកិនស្រូវ!

ធីតាៈ រោងម៉ាស៊ីននៅណា?

អ៊ូមៈ នៅខាងលិចផ្លូវ! កាលហ្នឹងថាដាំចំការដាំអីជាមួយកូនហើយគេចូលប្អូន!

ធីតាៈ កូនប៉ុន្មានទៅកាលនៅហ្នឹង?

អ៊ូមៈ គេថាកូន៤នាក់!

ធីតាៈ ឈ្មោះអីគេខ្លះ?

អ៊ូមៈ ខ្ញុំមិនចាំទេ!

ធីតាៈ ចុះនៅម្តុំនេះហ្នឹងគេអត់មានធ្វើអីផង អ្នកស្រុកភូមិហ្នឹងអត់មានធ្វើអីផង?

អ៊ូមៈ អត់មានធ្វើអីទេ!

ធីតាៈ ហើយផ្ទះអីហ្នឹងគេធ្វើតែស្រូវស្រែទេ?

អ៊ូមៈ ហ្នឹងអើយគេធ្វើស្រែធ្វើចំការដំឡូង!

ធីតាៈ ចុះហេតុអីបានអ៊ំបាត់ការចងចាំដោយសារមូលហេតុអី ដោយសារតែយើងភ័យខ្លាចពេកឬក៏ម៉េច?

អ៊ូមៈ ខ្ញុំវាមិនភ្លេច ហើយមិនដឹងថាប្ដីវត់ទៅនៅឆ្នាំណាផង!

ធីតាៈ មិនដឹងប្ដីវត់ទៅនៅឆ្នាំណាទេ?

អ៊ូមៈ អត់ដឹងទេ!

ធីតាៈ ហើយអត់ដឹងថាគាត់ស្លាប់ឬរស់ទេ?

អ៊ូមៈ អត់ដឹងទេ!

ធីតាៈ គាត់ចេញពីអ៊ំនៅឆ្នាំណាអ៊ំមានចាំទេ?

អ៊ូមៈ ទេអត់ចាំទេ! គេថាគេចល័តដល់ហើយបាត់រហូតទៅ!

ធីតាៈ សព្វថ្ងៃអ៊ំមានកូនប៉ុន្មាននាក់?

អ៊ូមៈ កូនមួយ កូនស្រី!

ធីតាៈ មានតែម្នាក់ដែលថាពរពោះហ្នឹងទេ?

អ៊ូមៈ មីពរពោះហ្នឹងងាប់ហើយ!

ធីតាៈ ពរពោះហ្នឹងស្លាប់?

អ៊ូមៈ ចា៎!

ធីតាៈ ម៉េចបានស្លាប់?

អ៊ូមៈ ចុះបើគេឲ្យអង្ករមួយកូនកែវដឹក ហើយឲ្យបបរព្រឹកល្ងាច!

ធីតាៈ ងាប់ក្នុងពោះឬក៏...?

អ៊ូមៈ កើតម៉ោហើយ! កាលហ្នឹងគេបបរ៣០គ្រួសារគេឲ្យអង្ករ៩កំប៉ុង កាលហ្នឹងឲ្យមីបងនោះយោលប្អូនហើយខ្ញុំវត់ទៅដឹកទឹកបបរ កាលនោះវាងាប់ទៅខ្ញុំចិញ្ចឹមមីបងបានរស់ ហើយកាលនោះដឹកដំឡូងមីងដឹកអី កាលហ្នឹងដើរកាត់វាលមីនាងអើយ ដើរហត់ពេកឈប់មួយភ្លែតហើយបានដើរទៅទៀត ហើយកាលនោះគេមិនឲ្យដាំអីជាឯកជនទេណា៎!

ធីតាៈ ចុះហេតុអីបានជាមានអង្ករទាំងឃ្លាំងៗ?

អ៊ូម៖ គេមិនឲ្យ គេបែកឲ្យគេបែកឲ្យយកមកបបរនៅផ្ទះតែគេឲ្យតែបន្តិចទេណា៎! គេឲ្យទៅបាយជាក្រុមម្នាក់មួយកូនចានប៉ុណ្ណេះ!

ធីតា៖ អញ្ចឹងសព្វថ្ងៃនេះអ៊ំរស់នៅតែម្នាក់ឯងទេ រស់នៅជាមួយកូនឬក៏នៅតែម្នាក់ឯង?

អ៊ូម៖ រស់នៅតែឯង!

ធីតា៖ ហើយមានចៅមានអី?

អ៊ូម៖ មានចៅពីរបីនាក់ហើយ!

ធីតា៖ ចុះភ្នែកហ្នឹងទើបតែឥលូវឬក៏យូរហើយ?

អ៊ូម៖ កើតយូរហើយតែខ្ញុំមិនបានទៅពេទ្យ ហើយគេថាម៉េចមិនទៅឲ្យគេបក វាបន្តិចតែវាឈឺ ពេលវាឈឺទៅក្បាលក៏ឈឺ វង្វេងៗហ្នឹងឥលូវមិនដឹងអីទេភ្លេចមុខភ្លេចក្រោយ ។

ធីតា៖ អ៊ំមានសមាជិកទាំងអស់១២នាក់មែនទេ?

អ៊ូម៖ ចា៎?

ធីតា៖ ១២នាក់មែនទេសមាជិកគ្រួសារ?

អ៊ូម៖ ចា៎!

ធីតា៖ ពេលបែកសម័យខ្មែរក្រហមហ្នឹងហើយនៅសល់ប៉ុន្មាននាក់?

អ៊ូម៖ បែកពីនោះម៉ោខ្ញុំនាំកូនជាមួយឪខ្ញុំនោះនៅជាមួយគ្នា មីប្រាង មីប្រេង មីប្រេម មីគ្នាញនៅធ្វើស្រែជុំគ្នានោះ ១៥វស្សាគេធ្វើមួយក្រុម ធ្វើស្រែណា៎!

ធីតា៖ ចា៎!

អ៊ូម៖ ដល់ធ្វើស្រែទៅសន្ទូងវាស្អក ដល់ពេលស្អកទៅក្រុមណាដែលមានត្រពាំងបែកគ្នាទៅ!

ធីតា៖ អញ្ចឹងអ៊ំអត់មានដឹងពីទំនាក់ទំនងរឿងរបស់ឌុចសោះ?

អ៊ូម៖ អត់បានដឹងទេព្រោះខ្ញុំមិនសូវបានជិតដិតហ្នឹងគាត់!

ធីតា៖ ចុះដូចថាឥលូវមានតុលាការមានអី អ៊ំមានដឹងពីរឿងតុលាការអត់?

អ៊ូម៖ តុលាកានៅណា?

ធីតា៖ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គេកាត់ទោសឌុចអ៊ំមានដឹងទេ?

អ៊ូម៖ អត់ដឹងទេ!

ធីតា៖ ហើយអ៊ំគិតថាឌុចជាមនុស្សយ៉ាងម៉េចដែរ?

អ៊ូម៖ គិតថាជាអ្នកស្រុកអ្នកភូមិមិនដឹងគិតថាម៉េចទេ! ទើបតែឮវិទ្យុគេផ្សាយថាតាឌុច!

ធីតា៖ ចា៎!

អ៊ូមៈ  គេហៅតាឌុចមែនទេ?

ធីតាៈ  ចា៎!

អ៊ូមៈ  នៅនេះគេហៅតាពិន!

ធីតាៈ  គេហៅតាហង់ ពិន ព្រោះគាត់ឈ្មោះតាហង់ ពិន!

អ៊ូមៈ  អ៎!

ធីតាៈ  ព្រោះគាត់មានឈ្មោះពីរ តាឌុច ឬក៏ហង់ ពិន ។

អ៊ូមៈ  អ៎!

ធីតាៈ  នៅនេះគេហៅហង់ ពិន នៅនោះគេហៅតាឌុច ។

អ៊ូមៈ  ខ្ញុំចេះតែឆ្ងល់ថាតាឌុចណាចេះ?

ធីតាៈ  ហង់ ពិនដែលគាត់ម៉ោលេងផ្ទះលេងអីហ្នឹង គាត់មានដែលម៉ោផ្ទះអ៊ំទេ?

អ៊ូមៈ  មិនដែលទេ មិនដែលបាននិយាយជាមួយគាត់ពីរឿងអញ្ចេះអញ្ចោះទេ!

ធីតាៈ  អញ្ជើងអរគុណច្រើនហើយអ៊ំ!

អ៊ូមៈ  ចា៎!

«ចប់»